# វិធានរបស់សហប្រជាជាតិសំរាប់ការពារអនីតិជន

# ដែលត្រូវបានដកហូតសេរីភាព

( អនុម័តដោយសេចក្តីសំរេចលេខ ៤៥/១១៣ ចុះថ្ងៃទី ១៤ ធ្នូ ១៩៩០ នៃមហាសន្និបាត)

## I- ទស្សនៈវិស័យជាមូលដ្ឋាន

១. ប្រព័ន្ធយុត្តិធម៌អនីតិជន ត្រូវការពារសិទ្ធិ និង សុវត្ថិភាព និង លើកស្ទួយសុខមាលភាពរាងកាយ និង សតិស្មារតីរបស់អនីតិជន ។ ការដាក់គុកត្រូវប្រើជាមធ្យោបាយចុងក្រោយបង្អស់ ។

២. គួរដកហូតសេរីភាពរបស់អនីតិជន តែក្នុងករណីដែលស្របនឹងគោលការណ៍ និងនីតិវិធីដែលមានចែងនៅក្នុងវិធាននៃអត្ថបទនេះ និង នៅក្នុងវិធានជាបទដ្ឋានអប្បបរមារបស់សហប្រជាជាតិសំរាប់ការគ្រប់គ្រងវិស័យយុត្តិធម៌អនីតិជន (វិធានក្រុងប៉េកាំង) ។ ការដកហូតសេរីភាពរបស់អនីតិជនជាសេចក្តីសំរេចចុងក្រោយបង្អស់ និងក្នុងរយៈពេលអប្បបរមាដែលចាំបាច់ និង គួរធ្វើតែក្នុងករណីពិសេសបំផុតប៉ុណ្ណោះ ។ រយៈពេលនៃការដាក់ទោសទណ្ឌត្រូវសំរេចដោយអាជ្ញាធរតុលាការ ដោយមិនបដិសេធលទ្ធភាពនៃការដោះលែងមុនពេលកំណត់ ។

៣. វិធាននៃអត្ថបទនេះមានបំណងកំណត់បទដ្ឋានជាអប្បបរមាដែលទទួលយកដោយសហប្រជាជាតិសំរាប់ការពារអនីតិជនដែលត្រូវបានដកហូតសេរីភាពគ្រប់បែបយ៉ាងទាំងអស់ ស្របតាមសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន និងក្នុងទស្សនៈកាត់បន្ថយផលនាំអោយខូចប្រយោជន៍នៃការឃុំឃាំងគប់ប្រភេទទាំងអស់ និងលើកតំកើងការរួមរស់ឡើងវិញក្នុងសង្គម ។

៤. វិធាននៃអត្ថបទនេះ ត្រូវអនុវត្តដោយឥតលំអៀង ដោយគ្មានការរើសអើងតាមរូបភាពបែបណាឡើយ ដូចជាពូជសាសន៍ ពណ៌សម្បុរ ភេទ អាយុ ភាសា សាសនា សញ្ជាតិ មតិនយោបាយ ឬមតិផ្សេងៗទៀត ជំនឿឬការអនុវត្តផ្នែកវប្បធម៌ ទ្រព្យសម្បត្តិ ស្ថានភាពកំណើត ឬ គ្រួសារ ប្រភពជាតិពន្ធ ឬសង្គម និង ពិការភាព ។ ត្រូវគោរព ជំនឿសាសនា និងវប្បធម៌ ការអនុវត្ត និងគោលគំនិតសីលធម៌របស់អនីតិជន ។

៥. វិធាននៃអត្ថបទនេះ ត្រូវបង្កើតឡើងដើម្បីធ្វើជាបទដ្ឋានស្រួល សំរាប់យោង និងដើម្បីផ្តល់ការលើកទឹកចិត្ត និងការណែនាំដល់អ្នកអាជីពទាំងឡាយដែលពាក់ព័ន្ធក្នុងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌អនីតិជន ។

៦. វិធាននៃអត្ថបទនេះ គួរមានជាស្រេចសំរាប់ចែកចាយដល់បុគ្គលិកយុត្តិធម៌អនីតិជនជាភាសាជាតិរបស់គេ ។ អនីតិជនដែលមិនស្ទាត់ជំនាញក្នុងភាសា ដែលនិយាយដោយបុគ្គលិកនៃទីកន្លែងឃុំឃាំងគួរមានសិទ្ធិទទួលអ្នកបកប្រែ ដោយឥតគិតថ្លៃនៅពេលណាចាំបាច់ ជាពិសេសក្នុងអំឡុងពេលពិនិត្យផ្នែកពេទ្យ និងនីតិវិធីផ្នែកវិន័យ ។

៧. ក្នុងករណីដែលសមស្រប រដ្ឋទាំងឡាយគួរបញ្ចូលវិធាននៃអត្ថបទនេះទៅក្នុងច្បាប់របស់ខ្លួន ឬធ្វើវិសោធនកម្មច្បាប់ របស់ខ្លួនស្របតាមវិធានទាំងនេះ ហើយគួរកំណត់ផ្លូវជួសជុលវិញចំពោះការប្រព្រឹត្តរំលោភវិធានទាំងនេះ រួមមាន ការជួសជុលរបួសដែលបង្កដោយអនីតិជន ។ រដ្ឋទាំងឡាយគួរតាមដានការអនុវត្តន៍វិធានទាំងឡាយនៃអត្ថបទនេះ ផងដែរ ។

៨. អាជ្ញាធរមានសមត្ថកិច្ច គួរព្យាយាមជាប្រចាំដើម្បីបង្កើនឱ្យសាធារណជនយល់ដឹងថា ការថែទាំអនីតិជនដែលជាប់ឃុំឃាំង និងការរៀបចំឱ្យពួកគេបានត្រឡប់មករកសង្គមវិញជាសេវាកម្មផ្នែកសង្គមដែលមានសារៈសំខាន់ជាទីបំផុត ហើយដើម្បីសំរេចគោលដៅនេះ គួរចាត់វិធានការដើម្បីបង្កើនការប្រាស្រ័យទាក់ទងរវាងអនីតិជន និងសហគមន៍មូលដ្ឋាន ។

៩. គ្មានផ្នែកណានៃវិធានទាំងនេះត្រូវបានបកស្រាយដើម្បីបដិសេធការអនុវត្តន៍ ឧបករណ៍ និងបទដ្ឋានរបស់សហប្រជាជាតិ និងឧបករណ៍ និងបទដ្ឋានសិទ្ធិមនុស្សដែលពាក់ព័ន្ធ ដែលទទួលស្គាល់ដោយសហគមន៍អន្តរជាតិ ដែលនាំឆ្ពោះទៅរកការធានាសិទ្ធិ ការថែទាំ និងការការពារអនីតិជន កុមារ និងមនុស្សក្មេងទាំងអស់រិតតែខ្លាំងឡើង ។

១០. ក្នុងករណីដែលការអនុវត្តន៍ជាក់ស្តែងនូវវិធានណាមួយដែលមាននៅក្នុងផ្នែក I ដល់ V (រួមទាំងផ្នែក V ផង) មានទំនាស់ និងវិធាននានាដែលមាននៅក្នុងផ្នែកនេះ ការប្រតិបត្តិតាមវិធាននានានៅក្នុងផ្នែកនេះ ត្រូវចាត់ទុកថាមានឧត្តមភាពជាង ។

## II. វិសាលភាព និងការអនុវត្តន៍វិធាននានានៃអត្ថបទនេះ

១១. សំរាប់គោលបំណងនៃវិធាននៃអត្ថបទនេះ និយមន័យដូចតទៅនេះគួរយកមកប្រើ :

ក) អនីតិជនគឺជាមនុស្សរាល់រូបដែលមានអាយុក្រោម ១៨ឆ្នាំ ។ ច្បាប់គួរកំរិតអាយុត្រឹមណាដែលនៅក្រោម អាយុនោះ មិនត្រូវអនុញ្ញាតឱ្យដកហូតសេរីភាពពីកុមារនោះទេ ។

ខ) ការដកហូតសេរីភាពមានន័យថា ទម្រង់ណាមួយនៃការឃុំឃាំង ឬដាក់ពន្ធនាគារ ឬការដាក់មនុស្សម្នាក់ឱ្យនៅក្នុងទីកន្លែងស្ថិតក្នុងការឃាមកាមសាធារណៈ ឬ ឯកជន ដែលមនុស្សនោះមិនអនុញ្ញាតឱ្យចាកចេញពីទីកន្លែងនោះតាមចិត្តរបស់គេ ហើយការឃុំឃាំងនេះបានអនុវត្តតាមបញ្ជាអាជ្ញាធរតុលាការ អាជ្ញាធររដ្ឋបាល ឬ អាជ្ញាធរសាធារណៈដទៃទៀត ។

១២. ការដកហូតសេរីភាព គួរអនុវត្តក្នុងក្របខ័ណ្ឌ និងកាលៈទេសៈ ដែលធានាការគោរពចំពោះសិទ្ធិមនុស្សរបស់អនីតិជន ។ អនីតិជនដែលជាប់ឃុំឃាំងក្នុងទីកន្លែងនានា គួរធានាបានអត្ថប្រយោជន៍ពីសកម្មភាព និងកម្មវិធីមានន័យដែលនឹងជួយលើកស្ទួយ និងទ្រទ្រង់សុខភាព និងស្វ័យគោរព (សេចក្តីថ្លៃថ្នូរ) របស់គេជួយបង្កើនស្មារតី ទទួលខុសត្រូវ និងជួយជំរុញឱ្យមានឥរិយាបថ និងជំនាញទាំងឡាយដែលនឹងជួយអនីតិជនក្នុងការបណ្តុះបណ្តាល សក្តានុពលរបស់គេឱ្យ ទៅជាសមាជិកនៃសង្គម ។

១៣. អនីតិជនដែលត្រូវដកហូតសេរីភាព ទោះបីជាមានហេតុផលណាមួយទាក់ទងនឹងឋានៈរបស់គេក៏ដោយមិនត្រូវបានបដិសេធនូវសិទ្ធិពលរដ្ឋ សេដ្ឋកិច្ច នយោបាយ សង្គម ឬវប្បធម៌ ដែលគេមានសិទ្ធិទទួលតាមច្បាប់ជាតិ ឬអន្តរជាតិ ហើយដែលមានសមត្ថភាពជាមួយការដកហូតសេរីភាព ។

១៤. ការការពារសិទ្ធិឯកត្តជនរបស់អនីតិជន ដែលទាក់ទងជាពិសេសនឹងនីត្យានុកូលភាពនៃការអនុវត្តនីវិធានការឃុំឃាំង ត្រូវតែបានធានាដោយអាជ្ញាធរមានសមត្ថកិច្ច ចំណែកទិសដៅនៃការបញ្ចូលឱ្យរួមរស់ក្នុងសង្គម គួរតែធានាតាមរយៈការពិនិត្យជាប្រក្រតី និង មធ្យោបាយត្រួតត្រាដែលអនុវត្តស្របតាមបទដ្ឋានអន្តរជាតិច្បាប់ និងបទបញ្ជា របស់ជាតិដោយអង្គការដែលបានបង្កើតត្រឹមត្រូវដែលទទួលការអនុញ្ញាតឱ្យទៅមើលអនីតិជន ហើយដែលមិនមែនជាអង្គការរបស់ទីកន្លែងឃុំឃាំង ។

១៥. វិធានទាំងឡាយនៃអត្ថបទនេះអនុវត្តចំពោះប្រភេទ និងទម្រង់ទាំងអស់នៃទីកន្លែងឃុំឃាំងដែលនៅទីនោះ អនីតិជនត្រូវបានដកហូតសេរីភាព ។ ផ្នែក I, II, IV និង V នៃវិធាននៃអត្ថបទនេះអនុវត្តចំពោះទីកន្លែងឃុំឃាំង និង ស្ថាប័នគ្រប់គ្រងទាំងអស់ ហើយផ្នែក III អនុវត្តជាពិសេសចំពោះអនីតិជនស្ថិតនៅក្នុងការឃាត់ខ្លួន ឬកំពុងរង់ចាំការ ជំនុំជំរះ ។

១៦. វិធានទាំងឡាយនៃអត្ថបទនេះត្រូវអនុវត្តនៅក្នុងបរិបទនៃលក្ខខ័ណ្ឌសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលគ្រប ដណ្តប់នៅក្នុងរដ្ឋជាសមាជិកនីមួយៗ ។

## III. អនីតិជនស្ថិតក្នុងការឃាត់ខ្លួន ឬកំពុងរង់ចាំការជំនុំជំរះ

១៧. អនីតិជនដែលឃុំឃាំងក្នុងសភាពនៃការឃាត់ខ្លួន ឬកំពុងរង់ចាំការជំនុំជំរះ ( "មិនទាន់ជំនុំជំរះ" ) ត្រូវសន្មត់ ថាជាមនុស្សគ្មានទោស ហើយត្រូវគ្រប់គ្រងគេក្នុងឋានៈជាអ្នកគ្មានទោស ។ ការឃុំឃាំងមុនពេលជំនុំជំរះត្រូវចៀសវាង ក្នុងករណីដែលអាចធ្វើបាន និង ត្រូវធ្វើត្រឹមតែក្នុងកាលៈទេសៈចាំបាច់បំផុតប៉ុណ្ណោះ ។ ដូច្នេះ ត្រូវធ្វើកិច្ចប្រឹងប្រែង ទាំងអស់ដើម្បីអនុវត្តវិធានការជំនួស ។ កាលណាត្រូវប្រើការឃុំឃាំងបណ្តោះអាសន្នដោយខានមិនបាន តុលាការអនីតិជន និង អង្គការស៊ើបអង្កេតត្រូវផ្តល់អាទិភាពខ្ពស់បំផុតដល់ការចាត់ការរឿងក្តីនោះអោយរួសរាន់បំផុត ដើម្បីធានាថា ការឃុំឃាំងត្រូវធ្វើក្នុងរយៈពេលខ្លីបំផុតដែលអាចធ្វើបាន ។ ជនជាប់ឃុំឃាំងដែលមិនទាន់បានជំនុំជំរះគួរ បំបែកចេញពីអនីតិជនដែលជាប់ទោសរួចហើយ ។

១៨. សភាពដែលអនីតិជនមិនទាន់ជំនុំជំរះត្រូវបានឃុំឃាំងនៅក្រោមសភាពនោះ ត្រូវស្របនឹងវិធានដែលចែងខាងក្រោម ដោយមានបទបញ្ញត្តិពិសេសបន្ថែមតាមការចាំបាច់ និង សមស្របដោយពិចារណាដល់សេចក្តីតម្រូវនៃសច្ចធារណ៍នៃនិរទោស រយៈពេលនៃការឃុំឃាំង និងស្ថានភាពគតិយុត្តិ និងកាលៈទេសៈរបស់អនីតិជន ។ បទបញ្ញត្តិ ទាំងនេះ រួមមានជាអាទិ៍ដូចតទៅនេះ :

ក) អនីតិជនត្រូវមានសិទ្ធិបានទទួលយោបល់ផ្នែកច្បាប់ និង អាចដាក់ពាក្យសុំជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ កាលណាមានជំនួយបែបនោះ និង អាចទាក់ទងជាប្រចាំជាមួយទីប្រឹក្សាច្បាប់របស់គេ ។ ភាពជាឯកជន និងការសំងាត់ត្រូវបានធានាដល់ការទាក់ទងទាំងនោះ ។

ខ) ក្នុងករណីដែលអាចធ្វើទៅបាន គួរផ្តល់ឱ្យអនីតិជននូវឱកាសធ្វើការងារ ដោយទទួលប្រាក់កំរៃ និងបន្តការអប់រំ ឬការហ្វឹកហ្វឺន ប៉ុន្តែមិនមែនតម្រូវឱ្យធ្វើដូច្នេះទេ ។ ការងារការអប់រំ ឬការហ្វឹកហ្វឺនមិនមែនជាមូលហេតុសំរាប់បន្តការឃុំឃាំងទេ ។

គ) អនីតិជនគួរទទួល និង រក្សាសំភារៈសំរាប់ការលំហែ និង កំសាន្តរបស់គេឱ្យតែស្របនឹងផលប្រយោជន៍នៃការគ្រប់គ្រងយុត្តិធម៌ ។

## IV. ការគ្រប់គ្រងទីកន្លែងឃុំឃាំងអនីតិជន

## ក. សំណុំរឿង

១៩. របាយការណ៍ទាំងអស់ រួមមានសំណុំរឿងផ្នែកច្បាប់ សំណុំរឿងពេទ្យ និងសំណុំរឿងខាងនីតិវិធីវិន័យ និង ឯកសារដទៃទៀតទាំងអស់ដែលទាក់ទងនឹងទម្រង់ ខ្លឹមសារ និងសេចក្ដីលំអិតនៃការចាត់ការលើអនីតិជន ត្រូវទុកដាក់នៅក្នុងសំណុំរឿងផ្ទាល់ខ្លួនជាសំងាត់ រក្សាសំណុំរឿងឱ្យត្រឹមត្រូវទាន់សម័យកាលទុកសំរាប់តែអ្នកដែលត្រូវបានអនុញ្ញាតឱ្យមើល និងរៀបចំក្នុងរបៀបណាដែលងាយនឹងមើលយល់ ។ ក្នុងករណីដែលអាចធ្វើទៅបាន អនីតិជនរាល់រូបត្រូវមាន សិទ្ធិតវ៉ាជំទាស់ហេតុការណ៍ណាមួយឬមតិណាដែលចុះនៅក្នុងសំណុំរឿងរបស់គេ ដើម្បីបើកឱ្យគេធ្វើការកែតម្រូវ សេចក្ដីណាដែលមិនជាក់លាក់គ្មានមូលដ្ឋានឬមិនត្រឹមត្រូវ ។ ដើម្បីអនុវត្តសិទ្ធិនេះ ត្រូវមាននីតិវិធីសំរាប់អនុញ្ញាតឱ្យ ភាគីទីបីដែលសមស្របមានសិទ្ធិអាន និងស្រាវជ្រាវពត៌មាននៅក្នុងសំណុំរឿងនោះតាមការស្នើសុំរបស់អនីតិជន ។ នៅពេលដោះលែងសំណុំរឿងរបស់អនីតិជនត្រូវបិទឱ្យជិត ហើយនៅពេលវេលាមួយសមស្របត្រូវលុបចោល ។

២០. គ្មានអនីតិជនណាម្នាក់ត្រូវទទួលទុកនៅក្នុងទីកន្លែងឃុំឃាំងណាមួយ ដោយគ្មានដីកាឃុំឃាំងសុពលពីអាជ្ញាធរតុលាការ អាជ្ញាធររដ្ឋបាល ឬអាជ្ញាធរសាធារណៈដទៃទៀតឡើយ ។ ខ្លឹមសារលំអិតនៃដីកានេះ ត្រូវចុះជាបន្ទាន់ ក្នុងសៀវភៅសំណុំរឿង ។ គ្មានអនីតិជនណាម្នាក់ត្រូវឃុំឃាំងនៅទីកន្លែងណាមួយដែលគ្មានសៀវភៅសំណុំរឿងបែបនោះ ទេ ។

## ខ. ការទទួលការចុះបញ្ជី ចលនា និង ការផ្ទេរ

២១. នៅគ្រប់ទីកន្លែងដែលអនីតិជនត្រូវបានឃុំឃាំងកំណត់ត្រាពត៌មានពេញលេញ និងមានសន្ដិសុខត្រូវរក្សាទុក សំរាប់អនីតិជនម្នាក់ៗដែលទីកន្លែងនោះទទួលយក :

ក) ពត៌មានអំពីអត្តសញ្ញាណរបស់អនីតិជន

ខ) ហេតុការណ៍ និង ហេតុផលសំរាប់ឃុំឃាំង និងអាជ្ញាធរឃុំឃាំង

គ) ថ្ងៃ និងម៉ោងទទួល ផ្ទេរ និង ដោះលែង

ឃ) លិខិតជូនដំណឹងដល់ឪពុកម្ដាយ និងអាណាព្យាបាលនៅរាល់ពេលទទួល ផ្ទេរ ឬ ដោះលែងអនីតិជនក្នុងការគ្រប់គ្រងរបស់គេនៅពេលឃុំឃាំង ។

ង) ពត៌មានពិស្តារអំពីបញ្ហាសុខភាពរាងកាយ និងសតិស្មារតី ដែលបានដឹងរួមមានការប្រព្រឹត្ត គ្រឿងញៀន និង សុរា ។

២២. ពត៌មានអំពីការទទួលទីកន្លែង ការផ្ទេរ និងការដោះលែងត្រូវផ្ដល់ឱ្យឪពុកម្ដាយ និង អាណាព្យាបាល ឬ សាច់ញាតិជិតដិតរបស់សាមីអនីតិជន ដោយគ្មានបង្អង់ ។

២៣. ភ្លាម។ដែលអាចធ្វើទៅបានបន្ទាប់ពីការទទួល ត្រូវធ្វើរបាយការណ៍ពេញលេញ និងពត៌មានដែល ទាក់ទងអំពីស្ថានភាពផ្ទាល់ខ្លួន និង កាលៈទេសៈរបស់អនីតិជនម្នាក់។ ហើយត្រូវដាក់ជូនរដ្ឋបាលនៃទីកន្លែង ឃុំឃាំង ។

២៤. នៅពេលទទួលត្រូវផ្ដល់ឱ្យអនីតិជនទាំងអស់នូវអត្ថបទមួយច្បាប់ ស្ដីពីវិធានសំរាប់គ្រប់គ្រង ទីកន្លែងឃុំឃាំង ព្រមទាំងលិខិតពិពណ៌នាអំពីសិទ្ធិ និងកាតព្វកិច្ចរបស់អនីតិជនជាប់ឃុំឃាំង ជាភាសាដែលគេ អាចយល់បាន រួមជាមួយនឹងអាស័យដ្ឋានរបស់អាជ្ញាធរមានសមត្ថកិច្ច មានភារកិច្ចទទួលពាក្យបណ្ដឹង ព្រមទាំងអាស័យដ្ឋានរបស់ ទីភ្នាក់ងារសាធារណៈ ឬឯកជន និងអង្គការនានា ដែលផ្ដល់ជំនួយផ្នែកច្បាប់ ។ ចំពោះអនីតិជនទាំងឡាយដែល មិនចេះអក្សរ ឬដែលមិនអាចយល់ភាសាដែលសរសេរនៅលើទំរង់បែបបទ ពត៌មានត្រូវ បញ្ជូនក្នុងរបៀបមួយដែលធ្វើឱ្យ បានយល់ពេញលេញ។

២៥. ត្រូវជួយអនីតិជនទាំងអស់អោយយល់បទបញ្ជាគ្រប់គ្រងការរៀបចំផ្ទៃក្នុងរបស់ទីកន្លែងឃុំឃាំង គោលដៅ និងវិធីសាស្ត្រនៃការថែទាំដែលទីកន្លែងនោះផ្ដល់ឱ្យលក្ខខ័ណ្ឌតម្រូវនឹងនីតិវិធីផ្នែកវិន័យវិធីផ្សេង។ ដែលអនុញ្ញាតអោយ ប្រើដើម្បីស្វែងរកពត៌មាន និងដើម្បីធ្វើពាក្យបណ្ដឹង និងរឿងដទៃទៀតណាដែលចាំបាច់ ដើម្បីធ្វើឱ្យគេយល់ច្បាស់អំពី សិទ្ធិ និងកាតព្វកិច្ចរបស់គេនៅក្នុងអំឡុងពេលឃុំឃាំង ។

២៦. ការដឹកនាំអនីតិជនត្រូវប្រព្រឹត្តទៅដោយរដ្ឋបាលនៃទីកន្លែងឃុំឃាំងជាអ្នកចំណាយសោហ៊ុយ ដឹកនាំ ហើយយានជំនិះដឹកនាំនោះ ត្រូវមានខ្យល់ និងពន្លឺគ្រប់គ្រាន់ក្នុងលក្ខខ័ណ្ឌដែលមិនធ្វើឱ្យអនីតិជន រងការលំបាកវេទនា ឬអស់សេចក្ដីថ្លៃថ្នូរ ។ មិនត្រូវផ្ទេរអនីតិជនពីកន្លែងមួយទៅកន្លែងមួយតាមទំនើងចិត្ត ឡើយ ។

**គ. ការចាត់ថ្នាក់ និងការទុកដាក់**

២៧. ភ្លាម១ដែលធ្វើទៅបានបន្ទាប់ពីពេលទទួល ត្រូវសម្ភាសន៏អនីតិជនម្នាក់១ និងត្រូវរៀបចំរបាយការណ៏ផ្នែកចិត្តសាស្ត្រ និងសង្គមដែលចង្អុលបង្ហាញកត្តាណាដែលទាក់ទងនឹងប្រភេទជាក់លាក់ និងក៏រិតការថែទាំ និងកម្មវិធីដែល អនីតិជនត្រូវការ ។ របាយការណ៏នេះរួមជាមួយរបាយការណ៏ដែលរៀបចំដោយមន្ត្រីពេទ្យដែលបានពិនិត្យអនីតិជននៅ ពេលទទួលចូលក្នុងទីឃុំឃាំង ត្រូវបញ្ជូនទៅនាយកទីកន្លែងនោះ ក្នុងគោលបំណងសំរេចត្រូវទុកដាក់អនីតិជនកន្លែងណាសមស្របជាងគេ នៅក្នុងទីកន្លែងឃុំឃាំង និងសំរេចយកប្រភេទ និងក៏រិតថែទាំ និងកម្មវិធីបែបណាដែលត្រូវការ និង ត្រូវចាត់ធ្វើ ។ នៅពេលណាតំរូវអោយមានការចាត់ចែងស្តារនីតិសម្បទាឡើងវិញ ហើយរយៈពេលនៃការស្នាក់នៅ នៅក្នុងទីកន្លែងឃុំឃាំងអនុញ្ញាតឱ្យធ្វើបុគ្គលិកដែលមានការហ្វឹកហ្វឺននៃទីកន្លែងឃុំឃាំង ត្រូវរៀបចំផែនការចាត់ចែងមួយជាលាយលក្ខណ៏អក្សរសំរាប់បុគ្គលម្នាក់១ដោយបញ្ជាក់ច្បាស់លាស់អំពីទិសដៅនៃការចាត់ចែង និង រយៈពេលមធ្យោបាយចាត់ចែងដំណាក់កាល និងការពន្យាដែលធ្វើឱ្យសំរេចទិសដៅនោះ ។

២៨. ការឃុំឃាំងអនីតិជនត្រូវធ្វើតែក្នុងលក្ខខ័ណ្ឌ ដែលយកចិត្តទុកដាក់ពេញលេញដល់សេចក្តីត្រូវការពិសេសណាមួយ ឋានៈ និងសេចក្តីត្រូវការពិសេសស្របតាមអាយុ បុគ្គលិកលក្ខណៈ ភេទ និងប្រភេទនៃបទល្មើស ព្រមទាំងសុខភាព សតិស្មារតី និងរាងកាយ និងដែលធានាការការពារ អនីតិជនពីឥទ្ធិពលគ្រោះថ្នាក់ និងស្ថានការណ៏គ្រោះថ្នាក់ប៉ុណ្ណោះ ។ លក្ខណៈវិនិច្ឆ័យគោលសំរាប់ការបំបែកពពួកផ្សេង១នៃអនីតិជនដែលត្រូវបានដកហូតសេរីភាព គឺការផ្តល់ប្រភេទថែទាំដែលសមស្របបំផុតទៅនឹងសេចក្តីត្រូវការពិសេស របស់សាម៉ីបុគ្គល និងការការពារបូរណភាពរាងកាយ ស្មារតី និង សីលធម៌ និងសុខភាពរបស់គេ ។

២៩. នៅគ្រប់ទីកន្លែងឃុំឃាំងទាំងអស់ អនីតិជនត្រូវបំបែកចេញពីមនុស្សពេញវ័យ លើកលែងតែអនីតិជននោះជាសមាជិកគ្រួសារតែមួយ ក្រោមលក្ខខ័ណ្ឌដែលក្តាប់បាន អនីតិជនអាចឱ្យទៅនៅជាមួយមនុស្សពេញវ័យ ដែលបានសំរាំង ដោយហ្មត់ចត់ជាផ្នែកនៃកម្មវិធីពិសេសដែលមានប្រយោជន៏ដល់សាម៉ីអនីតិជន ។

៣០. គួរបង្កើតទីកន្លែងឃុំឃាំងចំហសំរាប់អនីតិជន ។ ទីកន្លែងឃុំឃាំងចំហជាទីកន្លែងដែលមិនមាន ឬ មានវិធានការសន្តិសុខជាអប្បបរមា ។ មនុស្សនៅក្នុងទីកន្លែងឃុំឃាំងនោះត្រូវមានតិចបំផុតដែលអាចធ្វើបាន ។ ចំនួនអនីតិជនដែលជាប់ឃុំឃាំងនៅក្នុងកន្លែងបិទគួរមានតិចល្មម ដើម្បីឱ្យគេចាត់ចែងរក្សាបុគ្គលម្នាក់១បាន ។ គួរធ្វើវិមជ្ឈការទីកន្លែងឃុំឃាំង ហើយគួរមានទំហំមួយដែលជួយសំរាលការចូលជួប

និងការទាក់ទងរវាងអនីតិជន និងគ្រួសារ របស់គេ ។ ទីកន្លែងឃុំឃាំងតូចត្រូវបង្កើត និងបញ្ចូលទៅក្នុង បរិស្ថានសង្គមសេដ្ឋកិច្ច និងវប្បធម៌របស់សហគមន៍ ។

### ឃ. បរិស្ថានរូបវន្តនៃទីកន្លែងឃុំឃាំង និងទីកន្លែងស្នាក់នៅ

៣១. អនីតិជនដែលត្រូវបានដកហូតសេរីភាព មានសិទ្ធិបានទីកន្លែង និងសេវាកម្មដែលត្រូវតាមគ្រប់ លក្ខខ័ណ្ឌតម្រូវទាំងអស់នៃសុខភាព និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ។

៣២. ប្លង់នៃទីកន្លែងឃុំឃាំងសំរាប់អនីតិជន និងបរិស្ថានរូបវន្តនៃទីកន្លែងត្រូវសមស្របទៅនឹង គោលដៅចាត់ចែងនៅក្នុងកន្លែងឃុំឃាំងដើម្បីស្តារនីតិសម្បទា ដោយយកចិត្តទុកដាក់ខ្ពស់ដល់សេចក្តី ត្រូវការរបស់អនីតិជន ឱ្យមានភាពជាឯកជន ការលើកកម្លាំងវិញ្ញាណឱកាសបានចងមេត្រីភាពជាមួយគ្នាគេ និងការចូលរួមក្នុងកីឡា ការហាត់កាយសម្បទា និងសកម្មភាពលំហែ ។ ប្លង់និងរចនាសម្ព័ន្ធទីកន្លែង ឃុំឃាំង អនីតិជនត្រូវកាត់បន្ថយឱ្យនៅតិច ជាអប្បបរមានូវគ្រោះថ្នាក់អគ្គីភ័យ និងធានាការជន្លៀសចេញដោយ សុវត្ថិភាពពីទីកន្លែងឃុំឃាំងនោះ ។ ត្រូវមានប្រព័ន្ធសញ្ញាអាសន្នមានប្រសិទ្ធិភាពក្នុងករណីមានអគ្គីភ័យ ព្រមទាំងមាននីតិវិធីផ្លូវការ និងនីតិវិធីហាត់អនុវត្ត ដើម្បីធានាសុវត្ថិភាពរបស់អនីតិជន។ ទីកន្លែងឃុំឃាំងមិន ត្រូវតាំងនៅតំបន់ដែលគេដឹងថាមានគ្រោះថ្នាក់ដល់សុខភាព ឬ គ្រោះថ្នាក់ដទៃទៀតទេ ។

៣៣. កន្លែងដេកពួនជាធម្មតា គួរមានបន្ទប់ដេកជាក្រុមតូចៗ ឬមានបន្ទប់ដេកសំរាប់មនុស្សម្នាក់ៗ ដោយគិតទៅដល់ក៏រិតបទដ្ឋានក្នុងតំបន់ ។ នៅក្នុងម៉ោងដេកគួរមានការត្រួតពិនិត្យជាប្រចាំ និង ស្ងាត់នូវ កន្លែងដេកទាំងអស់ រួមមាន បន្ទប់ដេកម្នាក់ៗ និង បន្ទប់ដេកជាក្រុម ដើម្បីធានាការការពារដោយអនីតិជន ម្នាក់ៗ ។ ស្របតាមបទដ្ឋានក្នុងតំបន់ ឬក្នុងប្រទេស គួរផ្តល់ឱ្យអនីតិជនម្នាក់ៗនូវប្រដាប់សំរាប់ដេកដាច់ ដោយឡែកពីគ្នា និងគ្រប់គ្រាន់ដែលត្រូវសំអាត នៅពេលចេញឱ្យទុកដាក់ដោយមានរបៀបល្អ និង ផ្លាស់ប្តូរ ជាញឹកញាប់ដើម្បីធានាភាពស្អាតបាត ។

៣៤. ទីកន្លែងអនាម័យត្រូវស្ថិតនៅទីកន្លែងមួយ និងមានបទដ្ឋានគ្រប់គ្រាន់ដើម្បីឱ្យអនីតិជនរាល់រូប ប្រតិបត្តិស្របតាមសេចក្តីត្រូវការផ្នែករូបរាងកាយរបស់គេក្នុងលក្ខណៈមានភាពជាឯកជន និងក្នុងរបៀប ស្អាត និងសមរម្យតាមការតម្រូវ ។

៣៥. ការមានរបស់របរផ្ទាល់ខ្លួន គឺជាធាតុផ្សំជាមូលដ្ឋាននៃសិទ្ធិក្នុងភាពជាឯកជន និងជាធាតុផ្សំសំរាប់សុខមាលភាពចិត្តសាស្រ្តរបស់អនីតិជន ។ សិទ្ធិរបស់អនីតិជនរាល់រូបដើម្បីមានរបស់របរផ្ទាល់ខ្លួន និងមានទីកន្លែង ទុកដាក់គ្រប់គ្រាន់របស់របរទាំងនោះត្រូវតែបានទទួលស្គាល់ និងគោរពពេញទី ។ របស់របរផ្ទាល់ខ្លួនដែលអនីតិជនមិនចង់ទុកនឹងខ្លួន ឬដែលត្រូវបានរឹបអូសត្រូវទុកដាក់នៅកន្លែងមួយដែលមានការគ្រប់គ្រងដោយសុវត្ថិភាព ។ បញ្ជីរាយវត្ថុទាំងនោះត្រូវបានចុះហត្ថលេខាដោយអនីតិជន ។ គួរចាត់វិធានការរក្សារបស់ទាំងនោះឱ្យនៅក្នុងសភាពល្អ ។ របស់ទាំងនោះ និង ប្រាក់កាសត្រូវប្រគល់ឱ្យអនីតិជនវិញនៅពេលដោះលែង លើកលែងតែក្នុងករណីណាដែលអនីតិជនត្រូវបានអនុញ្ញាតអោយចាយប្រាក់នោះ ឬ ឱ្យផ្ញើទ្រព្យសម្បត្តិនោះចេញពីទីកន្លែងឃុំឃាំងរួចហើយ ។ បើអនីតិជនម្នាក់ទទួល ឬត្រូវឃើញថាមានថ្នាំពេទ្យ មន្រ្តីពេទ្យត្រូវសំរេចប្រើប្រាស់ថ្នាំនោះដូចម្តេច ។

៣៦. ក្នុងកំរិតដែលអាចធ្វើទៅបាន អនីតិជនត្រូវមានសិទ្ធិប្រើប្រាស់សំលៀកបំពាក់ផ្ទាល់ខ្លួនរបស់គេ ទីកន្លែងឃុំឃាំងត្រូវធានាថា អនីតិជនម្នាក់ៗមានសំលៀកបំពាក់ផ្ទាល់ខ្លួនសមស្របទៅតាមធាតុអាកាស និងគ្រប់គ្រាន់ដើម្បីធានាសុខភាពល្អ និង ដែលមិនធ្វើឱ្យអាប់អោន ឬបាត់បង់តំលៃជាមនុស្ស ។ អនីតិជនដែលដកចេញ ឬចាកចេញពីទីកន្លែងឃុំឃាំងក្នុងគោលបំណងណាមួយ ត្រូវតែបានអនុញ្ញាតអោយស្លៀកពាក់ខោអាវផ្ទាល់ខ្លួនរបស់ពួកគេ ។

៣៧. ទីកន្លែងឃុំឃាំងនីមួយៗត្រូវធានាថា អនីតិជនរាល់រូបទទួលបានចំណីអាហារដែលចំអិនត្រឹមត្រូវ និងដាក់ឱ្យបរិភោគនៅពេលបរិភោគធម្មតា និងមានគុណភាព និងបរិមាណគ្រប់គ្រាន់ទៅតាមបទដ្ឋានវិទ្យាសាស្រ្តអាហារ អនាម័យ និងសុខភាព ហើយបើអាចធ្វើទៅបានស្របតាមសេចក្តីតំរូវខាងសាសនា និងវប្បធម៌ ។ ទឹកផឹកស្អាតត្រូវមាន សំរាប់អនីតិជនគ្រប់ពេល ។

### ង. ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការងារ

៣៨. អនីតិជនរាល់រូបដែលមានអាយុត្រូវតែចូលរៀន មានសិទ្ធិទទួលការអប់រំដែលសមស្រប និងសេចក្តីត្រូវការ និង សមត្ថភាពរបស់គេ និងដែលធ្វើឡើងសំរាប់ត្រៀមរៀបចំខ្លួនគេឱ្យត្រឡប់ទៅកាន់សង្គមវិញ ។ ការអប់រំនោះត្រូវ ផ្តល់នូវខាងក្រៅទីឃុំឃាំង ក្នុងសាលារៀន សហគមន៍ ក្នុងករណីណាដែលអាចធ្វើទៅបាន ហើយទោះក្នុងករណីណា ក៏ដោយ ត្រូវបង្រៀនដោយគ្រូបង្រៀនដែលមានគុណសម្បត្តិ

តាមរយៈកម្មវិធីដែលបញ្ចូលជាមួយប្រព័ន្ធអប់រំរបស់ប្រទេស ដើម្បីឱ្យអនីតិជនអាចបន្តការអប់រំរបស់គេដោយគ្មានការពិបាកបន្ទាប់ពីការដោះលែងទៅ ។ រដ្ឋបាលនៃទីកន្លែង ឃុំឃាំងគួរយកចិត្តទុកដាក់ពិសេសដល់ការអប់រំអនីតិជន ដែលមានដើមកំណើតបរទេស ឬអនីតិជនដែលមាន សេចក្តីត្រូវការ ពិសេសខាងវប្បធម៌ ឬជាតិពន្ធុ ។ អនីតិជនដែលមិនចេះអក្សរ ឬមានការលំបាកខាងការយល់ដឹង ឬខាងការរៀនសូត្រត្រូវមានសិទ្ធិទទួលការអប់រំពិសេស ។

៣៩. អនីតិជនដែលមានអាយុលើសពីអាយុដែលត្រូវចូលរៀន ដែលប្រាថ្នាចង់បន្តការអប់រំរបស់គេ គួរបានអនុញ្ញាត និងលើកទឹកចិត្តឱ្យបន្តការអប់រំ ហើយគួរប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីផ្តល់សិទ្ធិដល់ពួកគេបានទទួលកម្មវិធីអប់រំសមស្រប ។

៤០. សញ្ញាប័ត្រ ឬវិញ្ញាបនប័ត្រអប់រំ ដែលផ្តល់អោយអនីតិជននៅពេលជាប់ឃុំឃាំងមិនត្រូវបញ្ជាក់អ្វីទាំងអស់ ដែលបង្ហាញថា អនីតិជននោះបានជាប់ក្នុងស្ថាប័នឃុំឃាំង ។

៤១. ទីកន្លែងឃុំឃាំងទាំងអស់ គួរផ្តល់ឱកាសដល់អនីតិជនបានចូលអានឯកសារក្នុងបណ្ណាល័យ ដែលមានសៀវភៅគ្រប់គ្រាន់ផ្នែកសិក្សា និងផ្នែកកំសាន្ត ព្រមទាំងមានទស្សនាវដ្តីសមស្របសំរាប់អនីតិជនដែលត្រូវបានលើកទឹកចិត្ត និងធ្វើឱ្យអនីតិជននោះប្រើប្រាស់បណ្ណាល័យនោះឱ្យបានជាប្រយោជន៍ដោយបរិបូណ៌ ។

៤២. អនីតិជនរាល់រូបត្រូវមានសិទ្ធិទទួលការហ្វឹកហ្វឺនវិជ្ជាជីវៈនៅក្នុងមុខរបរទាំងឡាយ ដែលទំនងជារៀបចំខ្លួន អនីតិជននោះសំរាប់ការងារក្នុងពេលអនាគត ។

៤៣. ដោយមានការយកចិត្តទុកដាក់ខ្ពស់ដល់ការជ្រើសរើសត្រឹមត្រូវខាងវិជ្ជាជីវៈ និងដល់សេចក្តីតម្រូវរបស់រដ្ឋបាល ស្ថាប័នឃុំឃាំង អនីតិជនត្រូវតែអាចជ្រើសរើសប្រភេទនៃការងារដែលគេចង់ធ្វើ ។

៤៤. បទដ្ឋានការពារទាំងអស់របស់ជាតិ និង អន្តរជាតិដែលអនុវត្តចំពោះពលកម្មកុមារ និងកម្មករក្មេងៗ ត្រូវ អនុវត្តចំពោះអនីតិជនដែលត្រូវបានដកហូតសេរីភាព ។

៤៥. ក្នុងករណីដែលអាចធ្វើបាន គួរផ្តល់ឱ្យអនីតិជននូវឱកាសដើម្បីបំពេញការងារដែលបានប្រាក់កំរៃ បើអាចធ្វើទៅបាននៅក្នុងសហគមន៍មូលដ្ឋានជាការងារបំពេញបន្ថែមទៅនឹងការហ្វឹកហ្វឺនវិជ្ជាជីវៈ ដែលផ្តល់ឱ្យអនីតិជនដើម្បីបង្កើនលទ្ធភាពរកការងារសមស្របនៅពេលដែលគេត្រឡប់ទៅសហគមន៍របស់គេវិញ ។ ប្រភេទនៃការងារដែលបំពេញនោះ គឺជាប្រភេទការងារដែលផ្តល់ការហ្វឹកហ្វឺនសមស្របដែលមាន

អត្ថប្រយោជន៏ដល់អនីតិជនបន្ទាប់ពីការដោះលែងទៅ ។ ការរៀបចំ និង វិធីធ្វើការងារដែលផ្ដល់នូវទីកន្លែងឃុំឃាំងត្រូវដូចគ្នាមែនទែនតាមដែលអាចធ្វើបាន ទៅនឹងវិធីធ្វើការងារស្រដៀងគ្នាក្នុងសហគមន៍ដើម្បីរៀបចំខ្លួនអនីតិជនឱ្យស្របនឹងសភាពជីវភាពការងារធម្មតា ។

៤៦. អនីតិជនរាល់រូបដែលបំពេញការងារត្រូវមានសិទ្ធិបានប្រាក់កំរៃសមស្រប ។ ផលប្រយោជន៏របស់អនីតិជន និង ផលប្រយោជន៏នៃការហ្វឹកហ្វឺនវិជ្ជាជីវៈមិនត្រូវដាក់ឱ្យនៅក្រោមគោលបំណងរកកំរៃសំរាប់ទីកន្លែងឃុំឃាំង ឬភាគីទីបីឡើយ ។ ចំណែកនៃប្រាក់រកបានរបស់អនីតិជនជា ធម្មតាត្រូវចាត់ទុកដោយឡែកជាប្រាក់សន្សំដែលត្រូវប្រគល់ឱ្យអនីតិជននៅពេលដោះលែង ។ អនីតិជនត្រូវមានសិទ្ធិប្រើប្រាស់សំណល់នៃប្រាក់រកបានទាំងនោះ ដើម្បីទិញរបស់របរសំរាប់ប្រើប្រាស់ផ្ទាល់ខ្លួន ឬដើម្បីសងអ្នករងគ្រោះដែលខូចខាតដោយសារបទល្មើសរបស់គេ ឬដើម្បីផ្ញើទៅឱ្យគ្រួសារ របស់គេ ឬជនដទៃទៀតនៅក្រៅទីកន្លែងឃុំឃាំង ។

## ច. ការកំសាន្ត

៤៧. អនីតិជនរាល់រូបមានសិទ្ធិមានពេលវេលាសមរម្យ សំរាប់ហាត់ប្រាណប្រចាំថ្ងៃដោយសេរីនៅទីស្រលះ មានខ្យល់ កាលណាធាតុអាកាសអំណោយផល ដែលនៅក្នុងពេលនោះគួរតែផ្ដល់ការហាត់លេងកំសាន្ត និងការហាត់កាយសម្បទា។ គួរផ្ដល់ទីធ្លា ទីតាំង និង បរិក្ខាគ្រប់គ្រាន់សំរាប់សកម្មភាពទាំងនេះ ។ អនីតិជនរាល់រូបគួរមានពេលវេលាបន្ថែម សំរាប់សកម្មភាពលំហែប្រចាំថ្ងៃមួយចំណែកនៃពេលវេលានេះគួរតែផ្ដោតទៅលើសិល្បៈ និងការបណ្ដុះបណ្ដាល ជំនាញសិប្បកម្ម បើអនីតិជនចង់បានដូច្នេះ ។ ទីកន្លែងឃុំឃាំងត្រូវធានាថា អនីតិជនម្នាក់ៗមានកាយសម្បទាអាចចូលរួមក្នុងកម្មវិធីដែល មានសំរាប់ការហាត់ប្រាណ ។ ការហាត់ប្រាណដើម្បីស្ដារសុខភាព និងការព្យាបាលត្រូវផ្ដល់ដោយ អនីតិជន ដែលត្រូវការនៅក្រោមការត្រួតពិនិត្យរបស់ពេទ្យ ។

## ឆ. សាសនា

៤៨. អនីតិជនម្នាក់ៗត្រូវអនុញ្ញាតឱ្យបំពេញសេចក្ដីត្រូវការខាងជីវភាពសាសនា និងស្មារតី ជាពិសេសដោយ ចូលរួមក្នុងពិធីសាសនា ឬការប្រជុំដែលរៀបចំឱ្យដោយកន្លែងឃុំឃាំង ឬដោយរៀបចំពិធីខ្លួនឯង និងដោយមាន សៀវភៅ ឬ របស់ចាំបាច់សំរាប់ការគោរព និងការប្រៀនប្រដៅសាសនាក្នុងក្រុមរបស់ខ្លួន ។ បើទីកន្លែងឃុំឃាំងមានចំនួនគ្រប់គ្រាន់នៃសាសនាណាមួយ តំណាងម្នាក់ ឬច្រើននាក់ដែលមានគុណសម្បត្តិនៃ

សាសនានោះត្រូវបានតែងតាំង ឬយល់ព្រមឱ្យប្រារព្ធពិធី និងមកជួយមើលសុខទុក្ខជាឯកជនជាមួយអនីតិជន តាមការស្នើសុំរបស់គេ ។ អនីតិជនរាល់រូប ត្រូវមានសិទ្ធិទទួល ការមកមើលសុខទុក្ខរបស់តំណាងនៃសាសនាណាមួយដែលគេជ្រើសរើស ព្រមទាំងសិទ្ធិមិនចូលរួមក្នុងពិធីសាសនា និងបដិសេធដោយសេរី មិនទទួលការអប់រំ ការឱ្យយោបល់ ឬការបំពាក់បំប៉នខាងសាសនា ។

## ជ. ការថែទាំផ្នែកពេទ្យ

៤៩. អនីតិជនរាល់រូបត្រូវទទួលការថែទាំផ្នែកពេទ្យគ្រប់គ្រាន់ ទាំងផ្នែកបង្ការ និងផ្នែកព្យាបាល រួមមានការថែទាំ ធ្មេញ ភ្នែក និង សុខភាពសតិស្មារតី ព្រមទាំងទទួលផលិតផលឱសថសាស្ត្រ និងចំណីអាហារតម ពិសេសតាមការបញ្ជាក់របស់ពេទ្យ ។ ការថែទាំផ្នែកពេទ្យទាំងអស់នោះ កាលណាអាចធ្វើទៅបានត្រូវផ្តល់ដល់អនីតិជនជាប់ឃុំឃាំងតាមរយៈ ទីកន្លែង និង សេវាកម្មសុខភាពសមស្របរបស់សហគមន៍ដែលទីកន្លែងឃុំឃាំងនោះស្ថិតនៅ ដើម្បីបង្ការការនិយាយ តិះដៀលអនីតិជន និង ដើម្បីលើកតំកើងសេចក្តីថ្លៃថ្នូរ និងការរួមរស់ឡើងវិញក្នុងសង្គម ។

៥០. អនីតិជនរាល់រូបមានសិទ្ធិទទួលការពិនិត្យពីគ្រូពេទ្យជាបន្ទាន់នៅពេលទទួលឱ្យចូលក្នុងទីកន្លែងឃុំឃាំងក្នុងគោលបំណងកត់ត្រាភស្តុតាងណាមួយនៃការព្យាបាលមិនត្រឹមត្រូវពីមុន និង រកឱ្យឃើញសភាពរាងកាយ ឬសតិស្មារតី តម្រូវឱ្យមានការយកចិត្តទុកដាក់ពីពេទ្យ ។

៥១. សេវាកម្មផ្នែកពេទ្យដែលផ្តល់ឱ្យអនីតិជនត្រូវព្យាយាមរាវរកនិងត្រូវព្យាបាលជម្ងឺផ្លូវកាយ ឬប្រសាទ ការប្រើប្រាស់សារជាតិ ឬសភាពដទៃទៀតដែលអាចបង្អាក់ដល់ការរួមរស់ឡើងវិញនៅក្នុងសង្គម ។ ទីកន្លែងឃុំឃាំងអនីតិជននីមួយៗត្រូវមានសិទ្ធិទទួលសេវាកម្មជាបន្ទាន់ពីមន្ទីរពេទ្យ និងបរិក្ខាសមស្របសំរាប់ចំនួន និងសេចក្តីត្រូវការនៃ មនុស្សនៅក្នុងកន្លែងឃុំឃាំង ព្រមទាំងបុគ្គលិកដែលហ្វឹកហ្វឺនសំរាប់ថែទាំបង្កាជម្ងឺ និងទទួលភារៈជម្ងឺអាសន្ន ។ អនីតិជនម្នាក់ៗ ដែលឈឺដែលប្រាប់ពីជម្ងឺរបស់ខ្លួន ឬដែលបង្ហាញរោគសញ្ញានៃការមិនស្រួលខាងរាងកាយ ឬសតិស្មារតី ត្រូវទទួលការ ពិនិត្យជាបន្ទាន់ពីមន្ត្រីពេទ្យ ។

៥២. មន្ត្រីពេទ្យដែលមានហេតុផលជឿថាសុខភាពផ្លូវកាយ ឬស្មារតីរបស់អនីតិជនត្រូវបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយសារការឃុំឃាំងដោយសារកូដកម្មអត់អាហារ ឬសភាពណាមួយនៃការឃុំឃាំងត្រូវ

រាយការណ៍រឿងនេះជាបន្ទាន់ ទៅឱ្យនាយកទីឃុំឃាំងនោះ ហើយនិងទៅអាជ្ញាធរឯករាជ្យដែលទទួលកិច្ចការការពារសុខមាលភាពរបស់អនីតិជន ។

៥៣. អនីតិជនដែលរងគ្រោះជម្ងឺប្រសាទ ត្រូវព្យាបាលក្នុងស្ថាប័នឯកទេសមួយនៅក្រោមការចាត់ចែងឯករាជ្យផ្នែកពេទ្យ ។ ដោយមានការគិតគូរជាមួយនឹងទីភ្នាក់ងារសមស្រប គួរប្រកាន់យកវិធានការ ដើម្បីធានាការបន្តការថែទាំសុខភាពខួរក្បាលជាចាំបាច់បន្ទាប់ពីពេលដោះលែងទៅ ។

៥៤. ទីកន្លែងឃុំឃាំងអនីតិជន គួរចាត់ធ្វើកម្មវិធីឯកទេសសំរាប់បង្កាការប្រព្រឹត្តគ្រឿងញៀន និង ស្តារនីតិសម្បទាឡើងវិញដែលគ្រប់គ្រងដោយបុគ្គលិកមានគុណសម្បត្តិ ។ កម្មវិធីទាំងនេះត្រូវស្របនឹងអាយុ ភេទ និង លក្ខខ័ណ្ឌផ្សេងៗ ទៀតរបស់អនីតិជនដែលពាក់ព័ន្ធ ហើយគួរមានកន្លែង និង សេវាកម្មកំចាត់ការញៀនដែលមានបុគ្គលិក មានការហ្វឹកហ្វឺន ស្ទាត់ជំនាញសំរាប់អនីតិជនញៀនថ្នាំ ឬ សុរា ។

៥៥. គួរឱ្យថ្នាំពេទ្យសំរាប់តែការព្យាបាលចាំបាច់ដែលមមានមូលដ្ឋានខាងពេទ្យប៉ុណ្ណោះ ហើយពេលណាអាចធ្វើទៅបានត្រូវឱ្យថ្នាំនោះបន្ទាប់ពីអនីតិជនបានយល់ដឹង និង យល់ព្រមលើការប្រើប្រាស់ថ្នាំនោះប៉ុណ្ណោះ ។ ជាពិសេសមិនត្រូវឱ្យថ្នាំទៅអនីតិជនដើម្បីឈ្លេចសួរយកពតិមាន ឬដើម្បីធ្វើឱ្យគេសារភាពដើម្បីដាក់ទណ្ឌកម្ម ឬធ្វើជាមធ្យោបាយសំរាប់ឃុំឃាំង ។ អនីតិជនមិនត្រូវធ្វើជារបស់សំរាប់ពិសោធន៍ការប្រើប្រាស់ថ្នាំ និងពិសោធន៍ការព្យាបាលដាច់ខាត ។ ការឱ្យថ្នាំណាមួយត្រូវតែមានការអនុញ្ញាត និងអនុវត្តដោយបុគ្គលិកពេទ្យ ដែលមានគុណសម្បត្តិជានិច្ច ។

### ឈ. ការជូនដំណឹងអំពីជម្ងឺ របួស និងមរណភាព

៥៦. គ្រួសារ ឬ អាណាព្យាបាលរបស់អនីតិជន និងជនដទៃទៀត ដែលចាត់តាំងដោយអនីតិជនមានសិទ្ធិត្រូវបានគេជំរាបពតិមានអំពីសភាពសុខភាពរបស់អនីតិជនតាមការស្នើសុំ និងនៅក្នុងពេលណាមានការប្រែប្រួលសំខាន់ ក្នុងសុខភាពរបស់អនីតិជន ។ នាយកទីកន្លែងឃុំឃាំងត្រូវជូនដំណឹងជាបន្ទាន់ដល់គ្រួសារ ឬអាណាព្យាបាលរបស់សាមុី អនីតិជន ឬជនដែលអនីតិជនបានចាត់តាំងក្នុងករណីមានមរណភាព មានជម្ងឺដែលតម្រូវឱ្យផ្ទេរអនីតិជនទៅកន្លែង ព្យាបាលខាងក្រៅ ឬក្នុងករណីមានសភាពណាមួយដែលតម្រូវឱ្យមានការថែទាំតាមដានជម្ងឺនៅក្នុងទីកន្លែងឃុំឃាំង លើសពី ៤៨ម៉ោង ។ គួរផ្តល់ ដំណឹងដល់អាជ្ញាធរកុងស៊ុលនៃប្រទេសដែលអនីតិជនបរទេសជាពលរដ្ឋនៃប្រទេសនោះ ។

៥៧. នៅពេលមរណភាពរបស់អនីតិជនក្នុងអំឡុងពេលដកហូតសេរីភាព សាច់ញាតិដែលជិតបំផុតត្រូវមានសិទ្ធិពិនិត្យមើលលិខិតមរណភាព មើលសព និង សំរេចយកវិធីចាត់ចែងសព ។ នៅពេលមរណភាពនៃអនីតិជនជាប់ឃុំឃាំងត្រូវមានការស៊ើបអង្កេតឯករាជ្យមួយដើម្បីរកមើលហេតុនៃមរណភាព ។ របាយការណ៍អំពីការស៊ើបអង្កេតត្រូវផ្តល់ឱ្យសាច់ញាតិជិតបំផុតនោះ ។ ការស៊ើបអង្កេតនេះក៏គួរធ្វើដែរ កាលណាមរណភាពនៃអនីតិជនកើតឡើងនៅក្នុងរយៈពេលប្រាំមួយខែ បន្ទាប់ពីថ្ងៃដោះលែងពីទីកន្លែងឃុំឃាំង ហើយកាលណាមានហេតុផលជឿថា មរណភាពនោះទាក់ទងនឹង រយៈពេលនៃការឃុំឃាំង ។

៥៨. ត្រូវជូនពត៌មានដល់អនីតិជនឱ្យបានមុនពេលមរណភាព ជម្ងឺ ឬរបួសធ្ងន់ធ្ងរនៃសមាជិកគ្រួសារបង្កើតតាមដែលអាចធ្វើទៅបាន ហើយត្រូវផ្តល់ឱកាសអោយអនីតិជនបានចូលរួមពិធីបូជាសព ឬទៅជួបសាច់ញាតិដែលឈឺធ្ងន់ ។

## ៣. ការជួបទាក់ទងជាមួយសហគមន៍

៥៩. ត្រូវផ្តល់រាល់មធ្យោបាយដើម្បីធានាថា អនីតិជនមានការប្រាស្រ័យទាក់ទងជាមួយភិពភខាងក្រៅដែលជាភាគផ្សំមួយនៃសិទ្ធិដើម្បីបានការថែទាំដោយត្រឹមត្រូវ និងក្នុងបែបជាមនុស្ស ហើយជាការសំខាន់ដល់ការត្រៀមអនីតិជន ដើម្បីត្រឡប់ទៅរកសង្គមវិញ ។ ត្រូវអនុញ្ញាតអោយអនីតិជនប្រាស្រ័យទាក់ទងជាមួយគ្រួសាររបស់គេ មិត្តភ័ក្រ្ត និងជនដទៃទៀត ឬតំណាងនៃអង្គការខាងក្រៅដែលមានឈ្មោះល្បី និងអនុញ្ញាតអោយចាកចេញពីទីឃុំឃាំងសំរាប់គោលបំណងអប់រំវិជ្ជាជីវៈ ឬគោលបំណងសំខាន់ៗដទៃទៀត ។ បើអនីតិជនកំពុងទទួលទោស ពេលវេលាដែលចំណាយ នៅខាងក្រៅទីកន្លែងឃុំឃាំង ត្រូវរាប់បញ្ចូលជាផ្នែកមួយនៃរយៈពេលនៃទោសទាំងអស់ ។

៦០. អនីតិជនរាល់រូបត្រូវមានសិទ្ធិទទួលការមកសាកសួរសុខទុក្ខជាប្រក្រតី និងជាញឹកញាប់ជាគោលការណ៍មួយអាទិត្យម្តង ហើយមិនត្រូវតិចជាងម្តងក្នុងមួយខែពីសំណាក់គ្រួសារ និងទីប្រឹក្សាច្បាប់ក្រោមកាលៈទេសៈដែលគោរពសេចក្តីត្រូវការខាងភាពជាឯកជនរបស់អនីតិជន និងការជួប និងកាប្រាស្រ័យទាក់ទងដោយគ្មានរិតត្បិតជាមួយគ្រួសារ និង អ្នកការពារក្តី ។

៦១. អនីតិជនរាល់រូបត្រូវមានប្រាស្រ័យទាក់ទងជាលាយល័ក្ខអក្សរ ឬតាមទូរស័ព្ទយ៉ាងតិចពីរដងក្នុងមួយអាទិត្យជាមួយមនុស្សដែលអនីតិជននោះជ្រើសរើស លើកលែងតែច្បាប់ដាក់កំហិត ហើយបើចាំបាច់

ត្រូវមានអ្នកជួយ ដើម្បីឱ្យអនីតិជនបានទទួលសិទ្ធិនេះដោយប្រសិទ្ធិភាព ។ អនីតិជនរាល់រូបត្រូវមានសិទ្ធិទទួលលិខិតឆ្លងឆ្លើយ ។

៦២. អនីតិជនត្រូវមានឱកាសឱ្យបានដឹងជាប្រក្រតីអំពីពត៌មាននានា តាមរយៈការអានកាសែត ទស្សនាវដ្តី និងការបោះពុម្ពផ្សាយដទៃទៀត និងតាមរយៈការស្តាប់ និងមើលកម្មវិធីវិទ្យុ និងទូរទស្សន៍ និងភាពយន្ត តាមរយៈការមកសួរសុខទុក្ខ នៃអ្នកតំណាងក្លឹប ឬអង្គការស្របច្បាប់ណាមួយដែលអនីតិជនមានការយកចិត្តទុកដាក់ ។

## ជ. ការកំរិតព្រំដែននៃការបង្ក្រាបរាងកាយ និង ការប្រើកំលាំង

៦៣. ការប្រើប្រាសឧបករណ៍សំរាប់បង្ក្រាប និងការប្រើកំលាំងសំរាប់គោលបំណងណាមួយ ត្រូវហាមឃាត់ លើកលែងតែមានចែងក្នុងវិធាន ៦៤ ខាងក្រោមនេះ ។

៦៤. ឧបករណ៍បង្ក្រាប និងកម្លាំងអាចប្រើបានតែក្នុងករណីពិសេសបំផុត គឺក្នុងករណីណាដែលវិធីបង្ក្រាបដទៃទៀតទាំងអស់បានប្រើអស់ហើយ ហើយត្រូវបរាជ័យ និងលុះត្រាណាតែមានការអនុញ្ញាតដោយជាក់ច្បាស់ និងបញ្ជាក់ដោយច្បាស់ និងបទបញ្ជា ។ ឧបករណ៍ទាំងនោះមិនត្រូវបណ្តាលអោយមានការអាម៉ាស់ ឬធ្វើអោយបាត់បង់តំលៃជាមនុស្ស ហើយត្រូវប្រើដាច់ខាតសំរាប់តែរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន ។ តាមបញ្ជារបស់នាយករដ្ឋបាល ឧបករណ៍បែប នោះអាចប្រើប្រាស់បានដើម្បីបង្ក្រាបអនីតិជនកុំអោយធ្វើរបួសខ្លួនឯង ធ្វើអោយរបួសដល់អ្នកដទៃ ឬបំផ្លាញធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិ ។ ក្នុងករណីបែបនេះនាយកត្រូវពិគ្រោះភ្លាមជាមួយបុគ្គលិកពេទ្យ និងបុគ្គលិកដទៃទៀតដែលពាក់ព័ន្ធ និង ត្រូវរាយការណ៍ដល់អាជ្ញាធររដ្ឋបាលថ្នាក់លើ ។

៦៥. ការកាន់ និងប្រើអាវុធដោយបុគ្គលិកត្រូវហាមឃាត់នៅក្នុងទីកន្លែងណាមួយ ដែលមានអនីតិជនជាប់ឃុំឃាំង ។

## ឋ. នីតិវិធីវិន័យ

៦៦. វិធានការ និងនីតិវិធីខាងវិន័យណាមួយ ត្រូវរក្សាការយកចិត្តទុកដាក់លើសុវត្ថិភាព និងជីវភាពមានសណ្តាប់ធ្នាប់

នៃសហគមន៍ ហើយត្រូវការពារសេចក្ដីថ្លៃថ្នូរពីកំណើតរបស់អនីតិជន និងទិសដៅគ្រឹះនៃការថែទាំនៅក្នុងស្ថាប័នឃុំឃាំង ពោលគឺបណ្ដុះស្មារតីយុត្តិធម៌ សេចក្ដីថ្លៃថ្នូរ និងការគោរពចំពោះសិទ្ធិជាមូលដ្ឋាននៃមនុស្សរាល់រូប ។

៦៧. វិធានការផ្នែកវិន័យទាំងអស់ដែលជាការប្រព្រឹត្តបែបឃោរឃៅ គ្មានលក្ខណៈជាមនុស្ស ឬធ្វើឱ្យខូចតម្លៃជាមនុស្សត្រូវហាមឃាត់ដាច់ខាត រួមមានទណ្ឌកម្មលើរូបរាងកាយ ការដាក់នៅក្នុងបន្ទប់ងងឹត ការឃុំទុកក្នុងទីកន្លែងបិទជិត ឬដាក់តែឯង ឬដាក់ទណ្ឌកម្មដទៃទៀត ដែលធ្វើអោយខូចដល់សុខភាពរាងកាយ ឬសតិស្មារតីរបស់សាមីអនីតិជន ។ ការបន្ថយរបបអាហារ និងការដាក់កំហិត ឬការបដិសេធឱ្យជួបជាមួយសមាជិកគ្រួសារត្រូវហាមឃាត់ ទោះបីក្នុងគោលបំណងណាក៏ដោយ ។ ការងារពលកម្មជានិច្ចជាកាលត្រូវគិតថាជាឧបករណ៍សំរាប់អប់រំ និងជាមធ្យោបាយ សំរាប់លើកស្ទួយសេចក្ដីថ្លៃថ្នូររបស់អនីតិជនក្នុងការត្រៀមខ្លួនរបស់គេដើម្បីត្រឡប់ទៅរួមរស់នៅក្នុងសហគមន៍វិញ ហើយមិនត្រូវយកការងារពលកម្មនេះមកធ្វើជាការដាក់ទណ្ឌកម្មផ្នែកវិន័យឡើយ ។ គ្មានអនីតិជនណាម្នាក់ត្រូវបានដាក់ទណ្ឌកម្ម លើសពីមួយដងសំរាប់ការល្មើសវិន័យតែមួយនោះឡើយ ។ ការដាក់ទណ្ឌកម្មជា សមូហភាពត្រូវហាមឃាត់ ។

៦៨. ច្បាប់នីតិបញ្ញត្តិ ឬបទបញ្ជាដែលអនុម័តដោយអាជ្ញាធររដ្ឋបាលមានសមត្ថកិច្ច ត្រូវកំណត់បទដ្ឋានទាក់ទងចំណុចដូចតទៅនេះ ដោយពិចារណាទាំងស្រុកលើលក្ខណៈគ្រឹះ សេចក្ដីត្រូវការ និងសិទ្ធិរបស់អនីតិជន ។

ក) អំពើដែលចាត់ទុកថាជាបទល្មើសផ្នែកវិន័យ ។

ខ) ប្រភេទ និងរយៈពេលនៃទណ្ឌកម្មផ្នែកវិន័យដែលអាចធ្វើលើអនីតិជន ។

គ) អាជ្ញាធរមានសមត្ថកិច្ចដាក់ទណ្ឌលកម្មនោះ ។

ឃ) អាជ្ញាធរដែលមានសមត្ថកិច្ចពិចារណាការប្ដឹងតវ៉ា ។

៦៩. របាយការណ៍នៃការប្រព្រឹត្តមិនត្រឹមត្រូវ ត្រូវដាក់ជូនអាជ្ញាធរមានសមត្ថកិច្ចជាបន្ទាន់ដែលត្រូវសំរេចដោយគ្មានការបង្អង់គ្មានហេតុផល ។អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើការពិនិត្យឱ្យហ្មត់ចត់លើរឿងនោះ។

៧០. គ្មានអនីតិជនណាម្នាក់ត្រូវទទួលទណ្ឌកម្មផ្នែកវិន័យទេ លើកលែងតែការដាក់ទណ្ឌកម្មនោះស្របដាច់ខាតជាមួយលក្ខខ័ណ្ឌនៃច្បាប់ និងបទបញ្ជាជាធរមាន ។ គ្មានអនីតិជនណាម្នាក់ត្រូវទទួលទណ្ឌកម្មទេ លើកលែងតែអនីតិជន នោះបានទទួលពត៌មានអំពីអំពើល្មើសដែលគេបានចោទប្រកាន់នោះតាមបែបមួយ

សមស្រប ដែលធ្វើឱ្យអនីតិជននោះ បានដឹងពេញលេញអំពីការប្រព្រឹត្តរបស់ខ្លួន ហើយគេបានផ្តល់ឱកាសត្រឹមត្រូវឱ្យអនីតិជននោះបានការពាររឿងរបស់គេ រួមមានសិទ្ធិតវ៉ាទៅអាជ្ញាធរមានសមត្ថកិច្ចឥតលំអៀង ។ សំណុំរឿង មូលរបស់គេត្រូវរក្សាទុកនៅគ្រប់វិធីជំនុំជំរះផ្នែក វិន័យទាំងអស់ ។

៧១. គ្មានអនីតិជនត្រូវមានមុខងារខាងវិន័យទេ លើកលែងតែមុខងារនៅក្នុងការត្រួតមើលសកម្មភាពសង្គម អប់រំ ឬកីឡា ឬក្នុងកម្មវិធីស្វ័យគ្រប់គ្រងដែលគេកំណត់ជាក់លាក់ ។

## ឌ. អធិការកិច្ច និង បណ្តឹង

៧២. អធិការដែលមានគុណសម្បត្តិ ឬ អាជ្ញាធរសមមូលដែលមានការចាត់តាំងត្រឹមត្រូវ ដែលមិនមែនជាមនុស្សរបស់រដ្ឋបាលនៃទីកន្លែងឃុំឃាំងត្រូវបានផ្តល់អំណាចឱ្យ ធ្វើអធិការកិច្ចជាប្រចាំនិងចាត់ធ្វើអធិការកិច្ចដោយមិនប្រាប់អោយ ដឹងជាមុនតាមគំនិតផ្តួចផ្តើមរបស់ខ្លួន ហើយត្រូវទទួលបានការធានាពេញលេញនូវឯករាជ្យភាពក្នុងការអនុវត្តន៏ការងារនេះ ។ អធិការត្រូវមានសិទ្ធិចូលជួបដោយគ្មានក៏រិតជាមួយមនុស្សទាំងអស់ដែលជានិយោជិត ឬជាមួយអ្នកធ្វើការនៅទី កន្លែងដែលមានអនីតិជនដែលត្រូវដកហូតសេរីភាពជាមួយអនីតិជនទាំងអស់ និង មានសិទ្ធិពិនិត្យមើលឯកសារទាំងអស់ របស់ទីកន្លែងឃុំឃាំងដោយគ្មានបន្ទុចបង្អាក់ ។

៧៣. មន្ត្រីពេទ្យដែលមានគុណសម្បត្តិដែលនៅអមអាជ្ញាធរអធិការកិច្ច ឬសេវាកម្មសាធារណៈសុខាភិបាលត្រូវចូលរួមក្នុងអធិការកិច្ច ក្នុងការវាយតម្លៃថាតើមានការប្រតិបត្តិតាមវិធានទាក់ទងនឹងបរិស្ថានរូបវន្ត អនាម័យ កន្លែង ដេកពួនចំណីអាហារ ការហាត់ប្រាណ និង សេវាកម្មផ្នែកពេទ្យដែរឬទេព្រមទាំងទិដ្ឋភាព ឬសភាពដទៃទៀតនៃជីវភាព នៅក្នុងការឃុំឃាំងដែលមានផលប៉ះពាល់ដល់សុខភាពរាងកាយ និង សតិស្មារតីរបស់អនីតិជន ។ អនីតិជនរាល់រូបត្រូវមានសិទ្ធិនិយាយជាមួយមន្ត្រីអធិការកិច្ចណាមួយ ។

៧៤. បន្ទាប់បីពីបញ្ចប់អធិការកិច្ច អធិការត្រូវដាក់ជូនរបាយការណ៍ណាមួយអំពីលទ្ធផលដែលរកឃើញ ។របាយការណ៍ត្រូវរាប់បញ្ចូលការវាយតម្លៃអំពីការដែលទីកន្លែងឃុំឃាំងប្រតិបត្តិតាមវិធាន នៃអត្ថបទនេះ និងបញ្ញត្តិទាក់ទងនៃច្បាប់របស់ប្រទេស និង ការស្នើមតិទាក់ទងនឹងជំហានដែលចាត់ទុកថាចាំបាច់ដើម្បីធានាការប្រតិបត្តិតាមវិធាននិងច្បាប់ទាំងនោះ ។ ហេតុការណ៍ណាដែលអធិការរកឃើញដែល

ហាក់ដូចជាបញ្ជាក់ថាមានការរំលោភបញ្ញត្តិច្បាប់ទាក់ទងនឹង សិទ្ធិរបស់អនីតិជន ឬប្រតិបត្តិការនៃទីកន្លែងឃុំឃាំងបានកើតឡើង ហេតុការណ៍នោះត្រូវបញ្ជាក់ប្រាប់ទៅអាជ្ញាធរមានសមត្ថកិច្ចដើម្បីស៊ើបអង្កេតនិងចាត់ការប្តឹងចោទប្រកាន់ ។

៧៥. អនីតិជនរាល់រូបគួរមានឱកាសធ្វើសំណូមពរ ឬបណ្តឹងទៅនាយកនៃទីកន្លែងឃុំឃាំង និងទៅតំណាងស្រប ច្បាប់របស់គេ ។

៧៦. អនីតិជនរាល់រូបត្រូវមានសិទ្ធធ្វើសំណូមពរ ឬបណ្តឹងដោយគ្មានការពិនិត្យលើខ្លឹមសារ ទៅរដ្ឋបាលកណ្តាល អាជ្ញាធរតុលាការ ឬអាជ្ញាធរសមស្របដទៃទៀតតាមខ្សែរយៈដែលបានអនុម័ត ហើយត្រូវមានសិទ្ធិទទួលការឆ្លើយតបដោយគ្មានបង្អង់ ។

៧៧. គួរប្រឹងប្រែងដើម្បីបង្កើតការិយាល័យឯករាជ្យមួយ (អ្នកតំណាងក្តី) ដើម្បីទទួល និងស៊ើបអង្កេតពាក្យបណ្តឹងដែលធ្វើដោយអនីតិជនដែលត្រូវបានដកហូតសេរីភាព និងដើម្បីជួយក្នុងការធ្វើឱ្យបានសំរេចការដោះស្រាយដោយសមធម៌ ។

៧៨. អនីតិជនរាល់រូបត្រូវមានសិទ្ធិស្នើសុំជំនួយពីសមាជិកគ្រួសារ ទីប្រឹក្សាច្បាប់ ក្រុមមនុស្សធម៌ ឬអ្នកដទៃទៀតតាមដែលអាចធ្វើទៅបាន ដើម្បីធ្វើពាក្យបណ្តឹង ។ គួរផ្តល់ជំនួយដល់អនីតិជនដែលមិនចេះអក្សរ បើគេត្រូវការប្រើសេវាកម្មនៃទីភ្នាក់ងារ និងអង្គការសាធារណៈ ឬឯកជន ដែលផ្តល់ផ្នែកច្បាប់ ឬដែលមានសមត្ថកិច្ចទទួលពាក្យបណ្តឹង ។

## ឈ. ការត្រឡប់មកកាន់សហគមន៍វិញ

៧៩. អនីតិជនទាំងអស់ត្រូវទទួលបានអត្ថប្រយោជន៍ពីការចាត់ចែង ដើម្បីជួយពួកគេត្រឡប់មកកាន់សង្គមវិញ ជីវភាពគ្រួសារ ការអប់រំ ឬការងារវិញ បន្ទាប់ពីការដោះលែង ។ គួរបង្កើតនីតិវិធីរួមមាននីតិវិធីសំរាប់ ដោះលែងមុនពេលកំណត់ និង ផែនការសកម្មភាពពិសេសក្នុងគោលបំណងនេះ ។

៨០. អាជ្ញាធរមានសមត្ថកិច្ចត្រូវផ្តល់ ឬធានាសេវាកម្មដើម្បីជួយអនីតិជន ក្នុងការរៀបចំខ្លួនឡើងវិញក្នុងសង្គម និងដើម្បីបន្ថយអារម្មណ៍ ឬគំនិតមិនគប្បីចំពោះអនីតិជននោះ ។ សេវាកម្មទាំងនេះត្រូវធានាក្នុង

ក៏រិតដែលអាចធ្វើបានថា អនីតិជនត្រូវបានផ្តល់ទីលំនៅសមរម្យ ការងារ សំលៀកបំពាក់ និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីទំនុកបំរុងខ្លួនគេនៅពេលដោះលែង ដើម្បីជួយសំរួលការរួមរស់ក្នុងសង្គមឡើងវិញឱ្យបានជោគជ័យ ។ ត្រូវពិគ្រោះជាមួយតំណាង នៃទីភ្នាក់ងារផ្តល់សេវាកម្មបែបនោះ ហើយតំណាងទាំងនោះត្រូវមានសិទ្ធិចូលជួបអនីតិជននៅពេលគេស្ថិតក្នុងមន្ទីឃុំឃាំង ក្នុងគោលបំណងជួយអនីតិជនទាំងនោះក្នុងការត្រឡប់មកកាន់សហគមន៍វិញ ។

## V. បុគ្គលិក

៨១. បុគ្គលិកត្រូវមានគុណសម្បត្តិ ហើយត្រូវមានចំនួនអ្នកឯកទេសគ្រប់គ្រាន់ជាអ្នកអប់រំអ្នកបង្ហាត់វិជ្ជាជីវៈ ទីប្រឹក្សា អ្នកធ្វើការខាងសង្គមកិច្ច អ្នកជំនាញខាងវិកលចរិត និង អ្នកចិត្តសាស្ត្រ ។ បុគ្គលិកទាំងនេះ និងបុគ្គលិកឯកទេសដទៃទៀត តាមធម្មតាត្រូវបំរើការងារជាលក្ខណៈអចិន្ត្រៃយ៍ ។ ការនេះមិនត្រូវផាត់ចោលអ្នកធ្វើការមិនពេញពេល ឬ អ្នកស្ម័គ្រចិត្តទេ កាលណាក៏រិតនៃការគាំទ្រ និង ការហ្វឹកហ្វឺនដែលអ្នកទាំងនេះផ្តល់ជាការសមស្រប និងមានអត្ថប្រយោជន៍ ។ ទីកន្លែងឃុំឃាំងត្រូវធ្វើឱ្យបានប្រយោជន៍នូវធនធានផ្នែកស្រោចស្រង់អប់រំ សីលធម៌ ស្មារតី និងធនធាន ដទៃទៀត និងទម្រង់ផ្សេងទៀតនៃជំនួយដែលសមស្រប និងមាននៅក្នុងសហគមន៍ យោងតាមសេចក្តី ត្រូវការនិងបញ្ហាផ្ទាល់ខ្លួនរបស់អនីតិជនជាប់ឃុំឃាំង ។

៨២. រដ្ឋបាលគួរសំរាំងជ្រើសរើសដោយហ្មត់ចត់នូវបុគ្គលិករាល់លំដាប់ថ្នាក់និងប្រភេទ ព្រោះថាការគ្រប់គ្រងដោយត្រឹមត្រូវនៃទីកន្លែងឃុំឃាំងអាស្រ័យលើភាពសុចរិត មនុស្សភាព សមត្ថភាព និង សមត្ថភាពវិជ្ជាជីវៈ ដើម្បីប្រឈមមុខជាមួយអនីតិជន ព្រមទាំងភាពសមស្របផ្ទាល់ខ្លួនរបស់បុគ្គលិកទាំងនោះទៅនឹងកិច្ចការ ។

៨៣. ដើម្បីបានសំរេចគោលបំណងដូចបានពោលកន្លងមកនេះ គួរតែងតាំងបុគ្គលិកជាមន្ត្រីអាជីពដោយផ្តល់ប្រាក់កំរៃគ្រប់គ្រាន់ដើម្បីទាក់ទាញ និងរក្សាទុកស្ត្រី និងបុរសដែលសមស្រប ។ បុគ្គលិកនៃទីកន្លែងឃុំឃាំងអនីតិជនត្រូវបានលើកទឹកចិត្តជាបន្តបន្ទាប់ឱ្យបំពេញករណីយកិច្ច និងកាតព្វកិច្ចរបស់គេក្នុងលក្ខណៈមនុស្សជាតិ ប្តេជ្ញាជាអ្នកអាជីពត្រឹមត្រូវ និងមានប្រសិទ្ធិភាព ដើម្បីប្រកាន់អាកប្បកិរិយាគ្រប់ពេលវេលាក្នុងបែបមួយដែលសមនឹងទទួលការគោរពពីអនីតិជន និង ដើម្បីធ្វើជាមនុស្សល្អដល់អនីតិជន ។

៨៤. រដ្ឋបាលគួរបញ្ចូនទម្រង់នៃការរៀបចំ និងគ្រប់គ្រងដែលជួយសំរួលការប្រាស្រ័យទាក់ទងប្រភេទផ្សេងៗ នៃបុគ្គលិកក្នុងទីកន្លែងឃុំឃាំងនីមួយៗ ដើម្បីបង្កើនសហប្រតិបត្តិការរវាងសេវាកម្មនានាដែលជាប់ជំពាក់ក្នុងការថែទាំអនីតិជន ព្រមទាំងរវាងបុគ្គលិក និងរដ្ឋបាល ក្នុងទស្សនៈធានាថាបុគ្គលិកដែលមានការទាក់ទងដោយផ្ទាល់ជាមួយអនីតិជន អាចបំពេញមុខងារក្នុងសភាពអំណោយផលដល់ការបំពេញករណីយកិច្ចរបស់គេដោយប្រសិទ្ធិភាព ។

៨៥. បុគ្គលិកត្រូវទទួលការហ្វឹកហ្វឺនណាមួយដែលអាចឱ្យគេអនុវត្តការទទួលខុសត្រូវរបស់គេដោយប្រសិទ្ធិភាព ជាពិសេសការហ្វឹកហ្វឺនក្នុងផ្នែកចិត្តសាស្រ្តកុមារ សុខមាលភាពកុមារ និងបទដ្ឋានអន្តរជាតិនៃសិទ្ធិមនុស្ស និងសិទ្ធិកុមារ រួមមានវិធាននៃអត្ថបទនេះ ។ បុគ្គលិកត្រូវរក្សា និងបង្កើតចំណេះដឹង និងសមត្ថភាពអាជីព ដោយចូលរួមក្នុងចន្លោះពេល សមរម្យក្នុងការងាររបស់គេ ។

៨៦. នាយកនៃទីកន្លែងឃុំឃាំងត្រូវមានគុណសម្បត្តិគ្រប់គ្រាន់សំរាប់កិច្ចការរបស់គេ ដោយមានសមត្ថភាពផ្នែករដ្ឋបាល និងការមានការហ្វឹកហ្វឺន និងការពិសោធន៍សមស្រប ហើយត្រូវអនុវត្តករណីយកិច្ចរបស់គេដោយពេញលេញ ។

៨៧. នៅក្នុងការបំពេញករណីយកិច្ចរបស់គេ បុគ្គលិកនៃទីកន្លែងឃុំឃាំងត្រូវគោរព និងការពារសេចក្តីថ្លៃថ្នូរ របស់មនុស្ស និងសិទ្ធិមនុស្សជាមូលដ្ឋានរបស់អនីតិជនទាំងអស់ ជាពិសេសដូចតទៅនេះ :

ក) - គ្មានសមាជិកណាម្នាក់នៃទីកន្លែងឃុំឃាំង ឬបុគ្គលិកនៃទីកន្លែងឃុំឃាំងអាចបង្កអុជអាល ឬអនុគ្រោះ អំពើទារុណកម្ម ឬទម្រង់ណាមួយនៃការប្រព្រឹត្តការដាក់ទណ្ឌកម្ម ការកែប្រែ ឬការប្រដៅដែលមាន លក្ខណៈព្រៃផ្សៃឃោរឃៅ អមនុស្សធម៌ ឬធ្វើឱ្យខូចតម្លៃជាមនុស្ស ដោយយកលេស ឬសំអាងលើ កាលៈទេសៈណាអ្វីទាំងអស់ ។

ខ) - បុគ្គលិកទាំងអស់ត្រូវប្រឆាំងម៉ឺងម៉ាត់ និងប្រយុទ្ធនឹងអំពើណាមួយដែលពុករលួយ ដោយរាយការណ៍ រឿងនេះទៅអាជ្ញាធរមានសមត្ថកិច្ចដោយគ្មានបង្អង់ ។

គ) - បុគ្គលិកទាំងអស់ត្រូវគោរពវិធានទាំងឡាយនៃអត្ថបទនេះ ។ បុគ្គលិកដែលមានហេតុផលជឿថា មានការរំលោភធ្ងន់ធ្ងរលើវិធានក្នុងអត្ថបទនេះបានកើតឡើង ឬរៀបនឹងកើតឡើង ត្រូវរាយការណ៍រឿងនេះទៅឱ្យអាជ្ញាធរថ្នាក់លើរបស់ខ្លួន ឬអង្គការណាដែលបានទទួល

អំណាចឱ្យពិនិត្យសើរើរឿង រំលោភ និងកេងយកប្រយោជន៍ខាងរាងកាយ ភេទ និង ស្មារតី ហើយត្រូវចាត់ការជាបន្ទាន់ដើម្បីឱ្យ បានការយកចិត្តទុកដាក់ផ្នែកពេទ្យពេលណាត្រូវការ ។

ង) - បុគ្គលិកទាំងអស់ត្រូវគោរពសិទ្ធិក្នុងភាពជាឯកជនរបស់អនីតិជន ហើយជាពិសេសត្រូវរក្សារឿងសម្ងាត់ទាំងអស់ទាក់ទងនឹងអនីតិជន ឬគ្រួសាររបស់គេ ដែលខ្លួនបានដឹងដោយសារឋានៈការងាររបស់ខ្លួន ។

ច) - បុគ្គលិកទាំងអស់ព្យាយាមបន្ថយភាពខុសគ្នាណាមួយឱ្យបានតិចបំផុតរវាង ជីវភាពនៅខាងក្នុង និង ខាងក្រៅទីកន្លែងឃុំឃាំង ដែលជាភាពខុសគ្នានាំទៅរកការបន្ថយការគោរពសេចក្តីថ្លៃថ្នូររបស់អនីតិជន ក្នុងភាពជាមនុស្ស ។